# អនុស្សរណៈនៃការយោគយល់គ្នា
# រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ
# និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការវាស់វែង
# និងខណ្ឌព្រំសីមាព្រំដែនគោក

** ** **

រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងគោលបំណងពង្រឹងថែមទៀត នូវចំណងមិត្តភាពរវាងប្រទេសទាំងពីរ

ដោយមានជំនឿទុកចិត្តថា ការខណ្ឌព្រំសីមាព្រំដែនគោក រវាងព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជា ជាប្រការមួយអាចជួយរារាំង និងដោះស្រាយនូវជំលោះព្រំដែន ដែលកើតមានឡើងតាមបណ្តោយព្រំដែន និងពង្រឹងបន្ថែមទៀត នូវទំនាក់ទំនងមិត្តភាពដែលមានរវាងប្រទេសទាំងពីរ ព្រមទាំងសំរួលដល់ការធ្វើដំណើរ និងសហប្រតិបត្តិការរវាងប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែន។

យោងដល់សេចក្តីប្រកាសរួមរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៤ ស្តីពីការយល់ព្រមបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនថៃ-កម្ពុជា នៅពេលសមស្របមួយ ។

យោងដល់សេចក្តីថ្លែងការណ៍រួម ស្តីពីការបង្កើតគណៈកម្មការចំរុះកិច្ចការព្រំដែនថៃ-កម្ពុជា ក្នុងការខណ្ឌសីមាព្រំដែនគោក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ដោយបានព្រមព្រៀងបង្កើតគណៈកម្មការចំរុះកិច្ចការព្រំដែនថៃ-កម្ពុជា ស្តីពីការខណ្ឌសីមាព្រំដែនគោករវាងប្រទេសទាំងពីរ ដែលមានភារកិច្ចបោះបង្គោលព្រំដែន ដើម្បីជាសញ្ញាសំគាល់ខ្សែព្រំដែន រវាងប្រទេសទាំងពីរ ។

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រា១

ការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក រវាងព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងរួមគ្នា ដោយសំអាងលើឯកសារដូចតទៅ :

(ក)-អនុសញ្ញារវាងបារាំង-សៀម ដែលបានកែប្រែអត្ថន័យ នៃសន្ធិសញ្ញា ថ្ងៃទី៣ ខែតុលា ឆ្នាំ ១៨៩៣ ទាក់ទងទៅនិងដែនដី និងការព្រមព្រៀងដ៏ទៃទៀត ដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ។

(ខ)-សន្ធិសញ្ញារវាងព្រះមហាក្សត្រសៀម និងលោកប្រធានាធិបតីនៃសាធារណៈរដ្ឋបារាំង ដែលបានចុះហត្ថលេខា នៅទីក្រុងបាងកក នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩០៧ និងពិធីសារស្តីពីការកំណត់ព្រំដែន ដែលជាឧបសម្ព័ន្ធ នៃសន្ធិសញ្ញា ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩០៧ និង

(គ) បណ្តាផែនទីដែលជាលទ្ធផល នៃកិច្ចការខ័ណ្ឌព្រំសីមារបស់គណៈកម្មការកំណត់ព្រំដែន ឥណ្ឌូចិន-សៀម ដែលបង្កើតឡើងតាមអនុសញ្ញាឆ្នាំ១៩០៤ និងសន្ធិសញ្ញាឆ្នាំ១៩០៧ រវាងបារាំង-សៀម និងឯកសារដទៃទៀត ដែលទាក់ទងទៅនិងការអនុវត្តន៍នៃអនុសញ្ញាឆ្នាំ១៩០៤ និងសន្ធិសញ្ញាឆ្នាំ១៩០៧ រវាងបារាំង-សៀម ។

## មាត្រា២

១-គណៈកម្មការចំរុះថៃ-កម្ពុជា ស្តីពីការខ័ណ្ឌសីមាព្រំដែនគោក ដែលហៅកាត់ថា " គណៈកម្មការចំរុះព្រំដែន " រួមមានសហប្រធានពីរ និងសមាជិកដ៏ទៃទៀត ដែលតែងតាំងដោយរដ្ឋាភិបាល នៃប្រទេសរៀង១ខ្លួន ។ អនុរដ្ឋមន្ត្រីក្រសួងការបរទេស នៃព្រះរាជាណាចក្រថៃ និងទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើជាសហប្រធាន ។ ការតែងតាំងសមាជិកដទៃទៀត ត្រូវជូនជាដំណឹងតាមរយៈការទូត រវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ក្នុងកំឡុងពេល១ខែបន្ទាប់ពីអនុស្សារណៈ នៃការយោគយល់គ្នាចូលជាធរមាន ។

២-គណៈកម្មការចំរុះព្រំដែន ត្រូវជួបប្រជុំផ្លាស់វេនគ្នា មួយឆ្នាំម្តងរវាងប្រទេសថៃ និងកម្ពុជា។ ប្រសិនជាចាំបាច់ គណៈកម្មការចំរុះអាចជួបប្រជុំវិសាមញ្ញ ដើម្បីពិភាក្សាពីបញ្ហាការងារក្នុងកំឡុងពេលជាបន្ទាន់ណាមួយ នឹងក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៣-បែបបទការងាររបស់គណៈកម្មការចំរុះព្រំដែន មានដូចតទៅ :

(ក)-ទទួលខុសត្រូវចំពោះការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ដោយយោងតាមមាត្រា១ ។

(ខ)-ពិនិត្យ និងអនុម័តលើបែបបទការងារ និងគំរោងប្លង់មេ សំរាប់ការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ។

(គ)-កំណត់តំបន់អទិភាព ដើម្បីធ្វើការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ។

(ឃ)-ចាត់តាំងភារកិច្ចវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោកដល់អនុគណៈកម្មការបច្ចេកទេសចំរុះដូចមានចែងក្នុងមាត្រា៣ គ្រប់គ្រងនិងត្រួតពិនិត្យរាល់ការអនុវត្តន៍ កិច្ចការរបស់អនុគណៈកម្មការនេះ ។

(ង)-ពិនិត្យរបាយការណ៍ ឬអនុសារ ដែលបានដាក់ជូនដោយអនុគណៈកម្មការបច្ចេកទេសចំរុះ ។

(ច)-ផលិតផែនទី នៃតំបន់ព្រំដែនដែលបានវាស់វែង និងខ័ណ្ឌសីមារួចហើយ ។

(ឆ)-ចាត់តាំងអនុគណៈកម្មការដ៏ទៃទៀត ដើម្បីទទួលនូវភារកិច្ចពិសេសណាមួយ ទៅតាមការចាំបាច់របស់ខ្លួន ។

មាត្រា៣

១-អនុគណៈកម្មការបច្ចេកទេសចំរុះ រួមមានសហប្រធាន២រូប និងសមាជិកដ៏ទៃទៀតដែលត្រូវបានចាត់តាំងដោយសហប្រធាន នៃគណៈកម្មការចំរុះកិច្ចការព្រំដែននៃភាគីនីមួយ ១ ។

២-បែបបទការងាររបស់អនុគណៈកម្មការបច្ចេកទេសចំរុះ មានដូចខាងក្រោមនេះ :

(ក) ពិនិត្យផ្ទៀងផ្ទាត់ទីតាំងពិតប្រាកដ របស់បង្គោលព្រំដែនទាំង៧៣ ដែលគណៈកម្មការ កំណត់ព្រំដែនឥណ្ឌូចិន-សៀម បានបោះក្នុងអំឡុងឆ្នាំ ១៩០៩ និង១៩១៩ ហើយរាយការណ៍អំពីការរកឃើញនោះ ជូនទៅគណៈកម្មការចំរុះកិច្ចការព្រំដែន ដើម្បីពិនិត្យ ។

(ខ) រៀបចំធ្វើបែបបទការងារ និងគំរោងប្លង់មេសំរាប់ការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ។

(គ) ចាត់តាំងក្រុមវាស់វែងចំរុះឱ្យអនុវត្តការវាស់វែង និងខ័ណ្ឌព្រំសីមាដែនគោក តាមការកំណត់របស់ គណៈកម្មការចំរុះកិច្ចការព្រំដែន ។

(ឃ) ធ្វើរបាយការណ៍ និងធ្វើអនុសាស្រ្តស្តីពីកិច្ចការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ជូនគណៈ

កម្មការចំរុះព្រំដែន ។

(ង) រៀបចំការផលិតផែនទី តំបន់ព្រំដែនគោកដែលបានវាស់វែង និងខ័ណ្ឌសីមារួចហើយ ។

(ច) ប្រសិនបើចាំបាច់ តែងតាំងតំណាងឱ្យចុះពិនិត្យការងារដល់ទីកន្លែងជាក់ស្តែង ជំនួសមុខឱ្យសហប្រធាននៃអនុគណៈកម្មការបច្ចេកទេសចំរុះ ។

(ឆ) ចាត់តាំងក្រុមការងារបច្ចេកទេសដទៃទៀត ដើម្បីជួយដល់កិច្ចការពិសេសណាមួយរបស់អនុគណៈកម្មការបច្ចេកទេសចំរុះ ។

៣- ក្នុងការអនុវត្តនីកិច្ចការវាស់វែង និងខ័ណ្ឌសីមាព្រំដែននៅតំបន់និមួយៗ ក្រុមវាស់វែងចំរុះត្រូវបានទទួលការធានារ៉ាប់រងជាបឋមពីការសំអាតមីន ក្នុងតំបន់ទាំងនោះ ។

## មាត្រា៤

១-ក្នុងគោលដៅធ្វើការវាស់វែង និងខ័ណ្ឌសីមាព្រំដែន ព្រំដែនគោករួមទាំងមូល ត្រូវបានបែងចែកជាកំណាត់ៗដោយអនុគណៈកម្មការបច្ចេកទេសចំរុះ ។

២-នៅពេលបញ្ចប់នៃការវាស់វែង និងខ័ណ្ឌសីមាព្រំដែនតំបន់នីមួយៗ អនុស្សារណៈនៃការយោគយល់គ្នាមួយ នឹងត្រូវចុះហត្ថលេខាដោយសហប្រធាននៃគណៈកម្មការចំរុះព្រំដែន ។ ផែនទីមួយដែលបង្ហាញពីតំណាក់កាលបញ្ចប់នៃការវាស់វែង និងខ័ណ្ឌសីមាព្រំដែន នឹងត្រូវបានចុះហត្ថលេខា និងបានភ្ជាប់ជាមួយនឹងអនុស្សារណៈនៃការយោគយល់គ្នានេះ ។

## មាត្រា៥

ដើម្បីសំរួលក្នុងការចុះពិនិត្យជាក់ស្តែង នៅតាមបណ្តោយព្រំដែនគោក ត្រូវបានហាមឃាត់ដល់អាជ្ញាធរដែនដី នៃប្រទេសនីមួយៗ និងភ្នាក់ងាររបស់ខ្លួនមិនឱ្យធ្វើការងារអ្វី ដែលអាចធ្វើឱ្យមានការប្រែប្រួលបរិស្ថាននៃតំបន់ព្រំដែននោះឡើយ លើកលែងតែការងារណា ដែលអនុគណៈកម្មការបច្ចេកទេសបានអនុម័ត សំរាប់សេចក្តីត្រូវការក្នុងការចុះពិនិត្យជាក់ស្តែង និងការខ័ណ្ឌសីមាព្រំដែនតែប៉ុណ្ណោះ ។

មាត្រា៦

១-រដ្ឋាភិបាលនីមួយៗ នឹងទទួលខុសត្រូវលើចំណាយផ្ទាល់ខ្លួនសំរាប់កិច្ចការវាស់វែង និងការងារខ័ណ្ឌសីមាព្រំដែន ។

២-តំលៃនៃសំភារៈសំរាប់ធ្វើបង្គោលព្រំដែន ឬបង្គោលសញ្ញាទាំងឡាយ ការរៀបចំនិងការផលិតផែនទី នៃការវាស់វែង និងការខ័ណ្ឌសីមាព្រំដែនគោក នឹងត្រូវចេញសោហ៊ុយចំណាយស្មើគ្នាដោយរដ្ឋាភិបាលទាំងពីរ ។

មាត្រា៧

១-រដ្ឋាភិបាលនៃប្រទេសទាំងពីរ នឹងត្រូវរៀបចំចាត់ចែងសំរុះសំរួលការងារចាំបាច់ទាក់ទងទៅនឹង ការងារអន្តោប្រវេសន៍ ចត្តាឡីស័ក និងគយ ដើម្បីសំរួលដល់ការអនុវត្តន៍វាស់វែង និងខ័ណ្ឌសីមាព្រំដែន ។

២-ជាពិសេស ចំពោះឧបករណ៍ សំភារៈ និងស្បៀងទៅតាមចំនួនសមស្រប និងសំរាប់ការប្រើប្រាស់ផ្ទាល់មុខរបស់ក្រុមវាស់វែង ក្នុងការវាស់វែង និងខ័ណ្ឌសីមាព្រំដែនគោក ទោះបីជាត្រូវបានយកឆ្លងកាត់ព្រំដែនក៏ដោយ ក៏មិនត្រូវចាត់ទុកថា ជាការនាំចេញ ឬនាំចូលពីប្រទេសមួយទៅប្រទេសមួយទៀតឡើយ នឹងមិនត្រូវជាប់ពន្ធគយ ឬពន្ធផ្សេងៗដែលទាក់ទងទៅនឹងការនាំចេញ ឬនាំចូលនោះទេ ។

មាត្រា៨

រាល់វិវាទដែលកើតមានឡើង បណ្តាលមកពីការបកស្រាយ ឬការអនុវត្តន៍អនុស្សារណៈនៃការយោគយល់គ្នានេះ នឹងត្រូវដោះស្រាយដោយសន្តិវិធី តាមរយៈការពិគ្រោះ និងការចរចាគ្នា ។

មាត្រា៩

អនុស្សារណៈនៃការយោគយល់គ្នានេះ នឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយតំណាងពេញសិទ្ធិនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីជាសក្ខីភាព អ្នកចុះហត្ថលេខាខាងក្រោម បានទទួលសិទ្ធិប្រទានត្រឹមត្រូវ ពីរដ្ឋាភិបាលនៃប្រទេសនីមួយៗ បានចុះហត្ថលេខានៅលើអនុស្សារណៈនេះ ។

ធ្វើនៅទីក្រុងភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ ជាពីរច្បាប់ ជាភាសាថៃ ភាសាខ្មែរ និងភាសាអង់គ្លេស អត្ថបទទាំងអស់នេះមានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា ឯកសារភាសាអង់គ្លេសនឹងត្រូវយកមកធ្វើជាឯកសារគោល ។

ជ.រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

**សុខុមបាន ប៉ារីប៉ាត្រា**

អនុរដ្ឋមន្ត្រីក្រសួងការបរទេស

នៃព្រះរាជាណាចក្រថៃ

ជ.រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

**វ៉ា គឹមហុង**

ទីប្រឹក្សារាជរដ្ឋាភិបាល

ទទួលបន្ទុកកិច្ចការព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៦ សប្រទ.

ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០

# សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់គណៈរដ្ឋមន្ត្រី

# រាជរដ្ឋាភិបាល

ប្រទានសិទ្ធិជូនឯកឧត្តម **វ៉ា គឹមហុង** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីចុះហត្ថលេខាលើអនុស្សរណៈស្តីពីការវាស់វែងនិងខណ្ឌព្រំសីមាព្រំដែនគោក រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ ក្នុងឱកាសទស្សនកិច្ចជាផ្លូវការរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃឡង់ នាថ្ងៃទី ១៤-១៦ មិថុនា ២០០០ នៅទីក្រុងភ្នំពេញ។

ដើម្បីជាសក្ខីភាពចំពោះការប្រគល់សិទ្ធិប្រទានជូន ឯកឧត្តម **វ៉ា គឹមហុង** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើលិខិតសិទ្ធិប្រទាននេះ។/.

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**